# ស្តាប់រឿងរ៉ាវ ដែលមកដល់តាមស្លាបនៃខ្យល់ជំនោរ

ខ្យល់ជំនោរថ្មីនេះដែលមានធ្លាប់មានពីមុនដែលបានធ្វើឲ្យដូរព្រៃឫស្សីលាន់លឺស្វូរក្រិកក្រុក បានបន្លឺសម្លេងរងំនៅក្នុងដុំសិលានៃភ្នំខ្ពស់ៗ បក់បោកកាត់តាមដីទំនាបដ៏មានជីជាតិ និងគ្មានដំណាំដែលនៅឆ្ងាយសន្ធឹមនៅទិសខាងជើង និងខាងត្បូង។ ខ្យល់ជំនោរនេះដែលមកបក់មកត្រសៀកនៅខាងក្នុងព្រៃដ៏សែនជ្រៅ លាន់ស្វូរសន្ធឹកលើផ្ទៃសមុទ្រ ហើយសម្លេងខ្សឹបខ្សៀវរបស់វាលាន់លឺដល់មនុស្សលោកនៅក្នុងទីប្រជុំជននានា ក្នុងភូមិ ក៏ដូចជាលំនៅឋានដែលនៅពីចំងាយ ស្ងាត់ដាច់ពីគេឯង។ខ្យល់ជំនោរអមតៈ ដែលបក់មក ហើយបក់ទៅបាត់ និងត្រលប់មកវិញម្តងទៀតជាថ្មី។

ស្តាប់រឿងរ៉ាវនេះដែលនៅក្នុងភាពផ្តាច់មុខរបស់វាបានកើតឡើងជាច្រើនលើករួចមកហើយ។ទីនោះជាទីដែលអតីតកាល និងអនាគត រួមបញ្ចូលជាមួយបច្ចុប្បន្ន នៅខណៈពេលមួយដែលខ្លីដូចពន្លឺភ្លឺមួយភ្លែត ប៉ុន្តែមានភាពជ្រាលជ្រៅដូចជាសកលលោកទាំងមូល។ខណៈពេលមួយដ៏ស្រស់ស្អាតដែលអ្នកដឹងយ៉ាងជ្រាលជ្រៅ និងអរគុណចំពោះដែលយើងនៅតែមាន។

កាលពីរយៈពេលប៉ុន្មានពាន់ឆ្នាំកន្លងមកហើយ មានកសិករវ័យក្មេងម្នាក់ដែលមានឈ្មោះថាសំបូរបានរស់នៅជាមួយគ្រួសាររបស់គាត់ នៅចំកណ្តាលស្រុកមួយដែលមានភាពកក់ក្តៅ និងស្រស់ស្អាតហើយមានសភាពស្ងប់ស្ងាត់ ។ ខ្ទមជាច្រើនក្នុងភូមិរបស់ពួកគេបានលាក់ខ្លួននៅក្រោមព្រៃដ៏ធំដែលមានដើមឈើខ្ពស់ជាច្រើនឈរជាជួរដែលហ៊ុំព័ទ្ធដោយវាលស្រែស្រូវដែលគ្របដណ្តប់ធូលី និងស្ងួតហួតហែង។ មានតែភ្នំតូចៗនៅដាច់ពីគេកំពុងងើបផុតពីស្រុកវាលទំនាបលើជើងមេឃដ៏ផងឆ្ងាយនេះ។ជារឿយស្រមោលរបស់ភ្នំទាំងនោះបានយោលយោគនៅក្នុងអាកាសធាតុខ្យល់ដ៏ក្តៅគគុក ហាក់ដូចវាជាវត្ថុមានជីវិតអ៊ីចឹង។

នៅក្នុងសភាពក្តៅស្អុះស្អាប់នាពេលរសៀល សំបូរ និងប្រពន្ធរបស់គាត់ កូនរបស់គាត់ពីរនាក់ និងសត្វស្វាតូចមួយដែលមានឈ្មោះថាតូចបានអង្គុយនៅលើជណ្តើរកាំខាងលើបង្អស់លើផ្ទះឈើរបស់ពួកគេ ដែលត្រូវសាងសង់នៅលើសសរដ៏ខ្ពស់ជាច្រើន។ខ្យល់ត្រជាក់តិចៗបានបក់ផាត់ភាពស្អុះស្អាប់ឲ្យបានត្រជាក់បន្តិចម្តង បន្តិចម្តង។ដំបូលដែលទ្រេត និងដើមឈើដែលនៅក្បែរនោះបានផ្តល់ជាស្រមោលម្លប់បន្តិចដល់ក្រុមគ្រួសារនេះ។

ពួកគេកំពុងរង់ចាំទឹកភ្លៀងដែលមិនបានបង្អុរមកអស់រយៈពេលជាយូរមកហើយនៅក្នុងឆ្នាំនេះ។ពួកគេមិនអាចចាប់ផ្តើមកិច្ចការធ្វើស្រែដ៏ចាំបាច់របស់ពួកគេឲ្យទាន់ពេលវេលាដ៏ត្រឹមត្រូវដោយគ្មានទឹកភ្លៀងបាននោះទេ។ ការប្រមូលផលស្រូវឆ្នាំមុន គឺមិនបានល្អសោះ ហើយការផ្គត់ផ្គង់អង្ករសម្រាប់ក្រុមគ្រួសារកំពុងតែថយចុះទាបយ៉ាងឆាប់រហ័ស។ សំបូរ ដឹងថាឈ្លូញឈ្មោះសុ

ខាមិនអាចឲ្យគាត់ខ្ចីអង្ករបានថែមទៀតទេនៅក្នុងស្ថានភាពនេះ។គាត់មានក្តីកង្វល់អំពីគ្រួសាររបស់គាត់ និងអំពីភូមិរបស់គាត់ ពីព្រោះស្ថានភាពក្រុមអ្នកជិតខាងរបស់គាត់មិនមានភាពប្រសើរជាងមុនសោះ ។ស្រុកទាំងមូលកំពុងអស់លទ្ធភាពបន្តិចម្តង ក្នុងការប្រយុទ្ធនឹងការស្រេកឃ្លាន។

ភាពក្តៅល្មម និងការបោសអង្អែលស្រាលរបស់ខ្យល់ជំនោរពេលរសៀលនៅក្នុងបរិវេណរង្វង់របស់ដើមឈើដែលនៅក្បែរបានធ្វើឲ្យសមាជិកគ្រួសាររបស់សំបូរលង់លក់ម្តងម្នាក់ ម្តងម្នាក់លើកន្ទេលពួកគេដែលពួកគេក្រាលនៅពីក្រោយទ្វារចូលផ្ទះរបស់ពួកគេ។សំបូរក៏បានចាប់ផ្តើមត្រៀមខ្លួនដេកផងដែរ។

រំពេចនោះ សត្វស្វាតូច ឈ្មោះតូចនោះបានរត់ឆ្លេឆ្លាចុះឡើងមិនឈប់ឈរនៅក្បែរគាត់។ សំបូរបានបើកភ្នែករបស់គាត់ និងបានក្រោកអង្គុយ។ចំពោះគាត់វាហាក់ដូចជារូបរាងសណ្ឋានព្រាលៗមួយនៃភ្នំតូចពីចម្ងាយបានកំពុងលេចរូបរាងឡើងបន្តិចម្តងៗ។ ចលនារបស់ពួកគេ គឺកំពុងកាន់តែច្បាស់ឡើង និងធូលីដីហុយខ្លួលខ្មាញ់ដែលបានកើនឡើងជុំវិញពួកគាត់កំពុងកាន់តែរីកធំឡើង។ក្នុងខណៈពេលនោះ វាប្រាកដយ៉ាងច្បាស់ចំពោះគាត់ថា ហ្វូងដំរីដ៏ធំមួយកំពុងតែចូលខិតចូលជិតភូមិរបស់គាត់។ហេតុការណ៍នេះមានភាពមិនប្រក្រតី។ ផ្លូវបំលាស់ទីរបស់សត្វដំរីលាតនៅឆ្ងាយពីភូមិរបស់គាត់ណាស់។ វាគឺប្រហែលជាភាពរាំងស្ងួតហើយដែលធ្វើឲ្យមានការប្រែប្រួលនេះ។ក្រុមសត្វដំរីរកទឹកផឹកមិនបានគ្រប់គ្រាន់ផឹកក្នុងបរិវេណទឹកដីប្រក្រតីនោះ ហើយពួកវាបានចាប់ផ្តើមរងគ្រោះដោយសារការស្រេកទឹក។ពេលនេះពួកវាកំពុងតម្រង់មកតាមផ្លូវដែលជិតបំផុតឲ្យកាន់តែឆាប់តាមលទ្ធភាពមកកាន់ច្រាំងឆ្នេរទន្លេធំដែលស្ថិតដ៏ឆ្ងាយនេះ។

ហ្វូងដំរីបានឆ្លងកាត់ហួសតាមបណ្តោយភូមិរបស់គាត់រួចទៅហើយ នៅពេលដែលសំបូរបានសង្កេតឃើញថាដំរីញីមួយក្បាល ជាមួយកូនដំរីក្មេងខ្ចីរបស់វាបានឈប់នៅក្នុងដុំផ្សែងធូលីដ៏ខ្លួលខ្មាញ់។ សំបូរអាចមើលឃើញពីរបៀបដែលជើងកូនដំរីរលាស់ជើងពីការអស់កម្លាំងដោយសារការដើរជាហ្វូងយ៉ាងយូរ និងយ៉ាងលឿននោះ។ម្តាយរបស់កូនដំរីដូចជាវិលវល់សម្លឹងមើលទៅហ្វូងដំរីដែលកំពុងចាកចេញ បន្ទាប់មកក្រឡេកមកមើលកូនរបស់វា ហើយនឹងសម្លឹងមើលភាពសោះកក្រោះដែលត្រូវដុតកម្តៅដោយព្រះអាទិត្យ។ចុងក្រោយមេដំរីនោះក៏បានបកក្រោយ ហើយវា និងកូនរបស់វាបានចាប់ផ្តើមដើរសំដៅមករកភូមិនេះ ទៅរកខ្ទមដែលនៅជាយខាងក្រៅភូមិ ជាទីដែលសំបូរអង្គុយ មានភ្ញាក់ផ្អើល និងនិយាយស្ដីមិនចេញ។

ដំរីទាំងពីរក្បាលបានឈប់ នៅពេលពួកវាបានទៅដល់ស្រមោលម្លប់ដែលចាំងពីផ្ទះរបស់សំបូរ។សត្វមាន់ពីរក្បាលរបស់ប្រពន្ធរបស់សំបូរបានបញ្ចេញសម្លេងក្រិកក្រុកដោយក្តីភ្ញាក់ផ្អើល។ទោះជាយ៉ាងណាក៏ដោយ ក៏ពួកវាបានស្ងប់ស្ងាត់ទៅវិញ និងបានវិលត្រឡប់នៅកាន់កន្លែងដេករបស់ពួកវាវិញ ដោយកកាយដីពណ៌ត្នោតចេញ។ពួកវាបានសង្កេតសត្វដ៏ធំពីរក្បាល

ដែលកំពុងតែនឹងមកដល់ពីទីកន្លែងនោះដោយក្តីចង់ដឹង។

មេដំរីបានស្រង់បានក្លិនទឹក ហើយបានលាប្រមោយដ៏វែងរបស់វាសំដៅទៅរកអណ្តូងទឹកដែលនៅជិតបំផុត ជាទីដែលនៅតែមានទឹកខ្លះដែលនៅយ៉ាងជ្រៅ។

ចេញពីក្តីអាណិតអាសូរចំពោះសត្វដំរីទាំងនោះ សំបូរបានជម្នះសេចក្តីខ្លាចរបស់គាត់ពីសត្វព្រៃដ៏ធំទាំងនោះ ក៏ដូចជាក្តីបារម្ភថាគ្រួសាររបស់គាត់មិនត្រឹមតែអាចនឹងខ្វះអាហារទេ ហើយក៏អាចថែមទាំងខ្វះទឹកផឹកផងដែរនោះ។ គាត់បានចុះទៅដីហើយបានចាប់ផ្តើមដួសទឹកមួយធុង ហើយមួយធុងទៀតចេញពីអណ្តូង។ មេដំរីបានផឹកទឹកដោយក្តីរីករាយ ហើយបានចាក់ស្រោចលើខ្នងដែលក្តៅគគុករបស់កូនរបស់វាដើម្បីធ្វើឲ្យវាត្រជាក់។កូនដំរីបានចាប់ផ្តើមធូរស្រាលយ៉ាងឆាប់រហ័ស។បន្ទាប់មកទៀត ភ្លាមៗនោះនោះវាអាចបៅទឹកដោះម្តាយរបស់វាបាន។

បន្ទាប់មកដំរីទាំងពីរបានត្រលប់មកកាន់ម្លប់ខ្ទមរបស់សំបូរវិញ ជាទីដែលវានៅរហូតដល់ពេលយប់។ ទឹក ម្លប់ ការសម្រាកប៉ុន្មានម៉ោង និងគុម្ពោតព្រៃជាច្រើនគុម្ពដែលនៅក្បែរនោះទុកស៊ី បានជួយឲ្យមេដំរីថែទាំកូនរបស់វាបានយ៉ាងល្អ ហើយឆាប់ៗនោះ វាចាប់មានពោរពេញដោយកម្លាំងកំហែងជាថ្មី។នៅពេលព្រះអាទិត្យបានមកប៉ះជើងមេឃនៅទិសខាងលិច ហើយព្រះចន្ទមានពន្លឺស្រាលបានបង្ហាញខ្លួននៅលើមេឃ  អាកាសធាតុមានភាពកាន់តែត្រជាក់រួចជាស្រេចនោះ សត្វដំរីទាំងពីរបានត្រៀមខ្លួនរកផ្លូវត្រលប់ទៅរកហ្វូងរបស់ពួកវាវិញ។

មួយរំពេចនោះ កូនដំរីបានបន្ទន់ជើងខាងក្រោយរបស់វា និងបានអង្គុយងើបឡើងដូចមនុស្សម្នាក់អង្គុយ។ បន្ទាប់មកវាងក់ក្បាលដាក់សំបូរជាមួយនឹងប្រមោយរបស់វាក្នុងរយៈពេលជាយូរ ដែលទីបំផុតបានធ្វើឲ្យសំបូរហ៊ានចូលទៅជិតវា។ មេដំរីបានថយក្រោយចេញបន្តិចដោយក្តីស្ងៀមស្ងាត់។ នៅពេលសំបូរបានទៅកៀកនឹងកូនដំរី គាត់បានឃើញថា កូនដំរីកាន់អ្វីម៉្យាងតូច និងភ្លឺនៅប្រមោយរបស់វា។ បន្ទាប់មកកូនដំរីហុចត្បូងថ្មពណ៌ខៀវក្រម៉ៅដ៏ស្អាតដាក់ចូលក្នុងបាតដៃរបស់គាត់។ សំបូរមានការភ្ញាក់ផ្អើល គាត់មិនអាចនិយាយចេញទេ ដូច្នេះគាត់ក៏បានអោនក្បាលគោរពយ៉ាងទាបនៅពីមុខកូនដំរីដែលជាទំនៀមទម្លាប់មួយ។ហើយកូនដំរីនោះក៏បានអោនយ៉ាងទាបផងដែរ។ បន្ទាប់មកសម្លេងដ៏ច្បាស់មួយបានលាន់ឡើងនៅក្នុងត្រចៀករបស់សំបូរថា៖ «បើសិនជាជានិច្ចជាកាលអ្នកនឹងមានសេចក្តីអាណិតអាសូរ និងភាពសប្បុរសដូច្នេះ អ្នក ហើយនឹងអ្នកដើរតាមរបស់អ្នកនឹងរក្សាការស្វែងរកត្បូងកណ្តៀងខៀវដូចគ្នានៅក្នុងវាលស្រែរបស់ពួកអ្នក ហើយការឈឺចាប់ទាំងអស់នឹងត្រូវកាត់បន្ថយនៅក្នុងស្រុកនានារបស់ទុកអ្នកសម្រាប់មនុស្សជំនាន់ក្រោយជាច្រើនដែលនឹងមកដល់»។

ប្រពន្ធរបស់សំបូរបានអង្រួនស្មារបស់គាត់ថ្នមៗ។ សំបូរបានក្រោកអង្គុយនៅលើកន្ទេលរបស់គាត់ មានអារម្មណ៍វង្វេង

វង្វាន់។ព្រះអាទិត្យបានប៉ះនឹងជើងមេឃទៅទិសខាងលិច ហើយព្រះចន្ទដ៏ភ្លឺក៏បានប្រាកដខ្លួននៅលើមេឃ។ គ្មានស្លាកស្នាមដានរបស់ហ្វូងដំរីនោះទេ។សត្វស្វាឈ្មោះតូចកំពុងលោតលេងយ៉ាងរីករាយជុំវិញដើមឈើ ហើយក្មេងៗបានកំពុងចំអែរចំអន់ដាក់គ្នាទៅវិញទៅមកដោយចិត្តបរិសុទ្ធ។ គ្រប់យ៉ាងបានហាក់ដូចជាដូចគ្នានៅពេលវាយ៉ាងណានោះ មុនពេលគាត់បានដេកលង់លក់។ប៉ុន្តែនៅមានត្បូងកណ្តៀងតូចពណ៌ខៀវក្រម៉ៅនៅក្នុងបាតដៃរបស់សំបូរ ហើយប្រពន្ធរបស់គាត់បានកំពុងសម្លឹងមើលវាដោយនិយាយថាវាមិនគួរឲ្យជឿទេ។

សំបូរបានប្រាប់ប្រពន្ធគាត់ពីអ្វីដែលបានកើតឡើងចំពោះរូបគាត់។ចុងក្រោយពួកគេបានសម្រេចចិត្តថា បើសិនជាពួកគេមិនដឹងពីអ្វី ដែលពិតជាបានកើតឡើង ពួកគាត់នឹងលក់ត្បូងកណ្តៀងនេះនៅទីប្រជុំជន និងទិញអង្ករដែលវាស្ទើរតែអស់ទៅហើយនោះ។

នៅពេលសំបូរបានត្រលប់មកពីទីប្រជុំជនវិញជាមួយអង្ករផ្ទុកពេញដ៏ច្រើន ក្រុមអ្នកជិតខាងមកពីភូមិទាំងមូលបានមកជួបជុំ ហើយពួកគេបានសួរដោយក្តីចង់ដឹងពីសំបូរថា ពួកគាត់បានអង្ករមកដោយរបៀបណា។ សំបូរបានប្រាប់រឿងរ៉ាវដល់ពួកគេ ហើយក្រុមអ្នកជិតខាងជូនពរឲ្យគាត់មានសំណាងល្អ។នៅពេលសំបូរបានឃើញពីរបៀបដែលក្រុមជិតខាងរបស់គាត់ដ៏មានក្តីកង្វល់ បានចាប់ផ្តើមដើរត្រលប់ទៅកាន់ជង្រុកស្រូវទទេរស្អាតរបស់ពួកគេវិញនោះ គាត់មានក្តីអាណិតអាសូរយ៉ាងពន់ពេកចំពោះពួកគេ។គាត់បានសម្រេចចិត្តចែកអង្ករល្មមគ្រប់គ្រាន់ដល់ក្រុមគ្រួសារទាំងអស់ជារៀងរាល់ថ្ងៃ ខណៈការផ្គត់ផ្គង់របស់គាត់នៅគ្រប់គ្រាន់។

ក្រុមអ្នកជិតខាងមានក្តីរីករាយណាស់ នៅពេលគាត់បានប្រាប់ពួកគេ ដែលពួកគេបានផ្តល់ដើម្បីជួយសំបូររកត្បូងកណ្តៀងខៀវនានាទៀតដែលកូនដំរីបាននិយាយប្រាប់ មុនពេលភ្លៀងរដូវវស្សាមកដល់ ដោយមានទឹកជំនន់ជន់លិចស្រែពោរពេញដោយទឹកនោះ។

ហើយពួកគេបានធ្វើដូច្នេះមែន ដូចដែលពួកគេបានព្រមព្រៀងគ្នា អ្នកជិតខាងរបស់គាត់២០នាក់បានមកស្រែរបស់សំបូរ។ពួកគេបានជីកដី បានពិនិត្យមើលវា ហើយបានគរដីជាគំនរទាំងសងខាងតាមបណ្តោយអន្លង់ដែលពួកគេបានជីក។នៅពេលល្ងាចពួកគេបាននាំយកអង្ករទៅផ្ទះដោយក្តីសប្បាយចិត្ត ហើយបានអរគុណសំបូរ ចំពោះការជួយដល់ពួកគេនៅក្នុងស្ថានភាពដ៏លំបាកនេះ។

ប៉ុន្តែគ្មាននរណាម្នាក់អាចរកឃើញសូម្បីតែត្បូងថ្មដ៏មានតម្លៃមួយគ្រាប់តូច។ សំបូរមិនមានការកើតទុក្ខនោះទេ។គាត់រីករាយនឹងជួយដូចធម្មតា។ ប៉ុន្តែគាត់នៅតែជឿថាពាក្យសម្តីរបស់កូនដំរីនឹងក្លាយជាការពិតនៅថ្ងៃណាមួយមិនខាន។

ពួកគេទាំងអស់គ្នាបានបន្តការងាររយៈពេល២៤ថ្ងៃ។ ការរុករកនៅតែគ្មានលទ្ធផល ហើយពួកគេបានចាប់ផ្តើមកង្វល់ជាថ្មីថាតើពួកគេបានអ្វីបរិភោគទៅនៅពេលអង្ករអស់នោះ។ នៅថ្ងៃទី២៥ នៅពេលដែលគ្មានត្បូងថ្មមួយគ្រាប់ត្រូវគេរកឃើញនោះ ភ្លៀងបានចាប់ផ្តើមបង្អុរធ្លាក់ចុះ មុនដំបូងភ្លៀងធ្លាក់តិចៗ បន្ទាប់មកធ្លាក់កាន់តែច្រើន ហើយវាពេលវេលាមានមិនយូរសម្រាប់ការធ្លាក់ភ្លៀងរដូវវស្សាមកនោះឡើយ។អ្នកគ្រប់គ្នាមានក្តីរំភើប ហើយបានរួសរាន់ទៅកាន់លំនៅឋានដើម្បីត្រៀមខ្លួនពួកគេសម្រាប់កិច្ចការស្រែចម្ការដែលនឹងមកដល់ពេលខាងមុខនោះ។ ក្រុមកសិករបានថ្លែងអំណរគុណសំបូរជាថ្មីម្តងទៀត និងបានលួងលោមគាត់ថា បន្ទាប់ពីការប្រមូលផលហើយ សំណាងរបស់គាត់នឹងល្អប្រសើរឡើងយ៉ាងពិតប្រាកដ។

សំបូរក៏បានប្រញាប់ប្រញាល់ត្រៀមរៀបចំស្រែរបស់គាត់ សម្រាប់រដូវដាំដុះស្រូវដែលនឹងមកដល់ផងដែរ។ កិច្ចការស្រែចម្ការមានការហត់នឿយណាស់ ហើយវាបានធ្វើឲ្យសមាជិកគ្រួសាររបស់សំបូររវល់ទាំងអស់គ្នា ជារៀងរាល់ថ្ងៃ ចាប់ពីពេលថ្ងៃរះ ដល់ពេលថ្ងៃលិច អស់រយៈពេលជាច្រើនសប្តាហ៍។កន្លែងតែមួយនៅក្នុងស្រែរបស់គាត់ដែលសំបូរចៀសវាង មិនប៉ះពាល់អំឡុងពេលនេះ ទាំងអស់គឺជាអន្លង់មួយនោះដែលពួកគាត់បានជីកជាមួយក្រុមអ្នកជិតខាងរបស់គាត់នៅពេលពួកគេកំពុងរុករកត្បូងកណ្តៀងនានានោះ។

នៅពេលវេលានៃការចេញផ្កាស្រូវបានកន្លងទៅ ពេលវេលាស្រូវពេញវ័យក៏បានមកដល់។ វាលស្រែស្រូវនានានៅជុំវិញភូមិបន្តិចម្តង បន្តិចម្តងបានប្រែពណ៌របស់ពួកវាពីពណ៌បៃតងលឿង ទៅជាពណ៌លឿងមាស។ ទឹកត្រូវបានគេបង្ហូរចេញពីស្រែអស់ពេលជាយូរមកហើយ។ បន្ទាប់ពីថ្ងៃមួយដ៏ហត់នឿយ សំបូរកំពុងសម្រាកនៅកន្លែងមួយដែលគាត់ចូលចិត្តបំផុតគឺនៅលើជណ្តើរកាំលើបំផុតលើខ្ទមឈើរបស់គាត់។ព្រះអាទិត្យបានទើបតែលិចចុះ ហើយព្រះអាទិត្យទើបតែលិច ហើយព្រះចន្ទដែលមានពន្លឺភ្លឺច្បាស់កំពុងចាប់ផ្តើមនឹងរះឡើងពីលើជើងមេឃទិសខាងកើត។ រំពេចនោះពន្លឺភ្លឺភ្លែតពណ៌ខៀវមួយរបស់ព្រះអាទិត្យបានធ្វើឲ្យសំបូរមានការចាប់អារម្មណ៍។វាគឺជាចំណាំងផ្លាតរបស់ពន្លឺព្រះចន្ទមកពីផ្ទៃទឹកខ្លះ ថ្វីបើគេគិតថាមិនមែនជាដៃផ្លូវទឹកណាមួយដែលមានរយៈចម្ងាយឆ្ងាយរាប់សិបគីឡូម៉ែត្រក៏ដោយ។ ប៉ុន្តែចំណាំងផ្លាតនោះនៅតែជាការពិត ហើយវាបញ្ចេញពន្លឺយ៉ាងច្បាស់ដោយមានពណ៌ត្បូងកណ្តៀងពណ៌ខៀវក្នុងពេលរាត្រីដែលនឹងខិតចូលមកដល់។ បន្ទាប់មកសំបូរបានយល់ពីវា។ ពន្លឺនោះកំពុងចេញមកពីផ្ទៃទឹកបឹងដែលកើតឡើងពីអន្លង់មួយនៅក្នុងស្រែរបស់គាត់ដែលបំពេញទៅដោយទឹកភ្លៀង។ បន្ទាប់ពីត្រេកត្រអាលជាមួយសម្រស់នេះបានមួយស្របក់ សំបូរសង្កេតឃើញមានរលកប្រដេញតូចៗដ៏ល្អវិចិត្រនៅលើផ្ទៃទឹក ហើយគាត់បានដើរចេញសំដៅទៅរកបឹងដើម្បីមើលដោយក្តីចង់ដឹងចង់ឃើញ។

នៅពេលគាត់ទៅដល់បឹង គាត់បានឃើញថាវាដើរតួដូចជាជាទំនប់ទឹកមួយ ដែលហ៊ុំព័ទ្ធទៅភ្លឺស្រែ ដែលត្រូវលើកគេ

ខ្ពស់ផុតពីដីបើប្រៀបធៀបទៅនឹងវាលស្រែដែលនៅជុំវិញ។ដោយក្តីភ្ញាក់ផ្អើលរបស់គាត់ សំបូរដឹងថា នៅពេលវាលស្រែត្រូវទឹកជន់លិច ហ្វូងត្រីត្រូវជាប់នៅក្នុងបឹង។ ត្រីបានកំពុងធំធាត់ល្មមជាស្រេច ធ្វើចលនាយ៉ាងរស់រវើកធ្វើឱ្យផ្ទៃទឹកបឹងមានសភាពដូចដូចទឹករលក ចាប់សត្វល្អិតដែលហោះហើរ និងហែលក្នុងទឹក ។ សំបូរបាននៅទីនោះមួយសន្ទុះដោយមិនកម្រើក។ រំពេចនោះគាត់បានឮសម្លេងទទះស្លាបដ៏ធំ។សត្វហង្សពណ៌សពីក្បាលទើបតែហើរចុះប៉ប្រះផ្ទៃទឹកបឹង។ ពួកវាបានហិចហែលយ៉ាងស្រស់សង្ហារមួយស្របក់ ហើយបន្ទាប់មកក៏បានបាត់ស្រមោលពីទស្សនីយភាពរបស់សំបូរចូលក្នុងគុម្ពត្រែងដែលដុះនៅជ្រុងមួយក្នុងបឹងរបស់សំបូរ។

រាត្រីនោះសំបូរដេកមិនលក់សោះ។ ទីបំផុតគាត់បានយល់ពីសម្តីរបស់កូនដំរីនោះ។គាត់បានរកឃើញត្បូងកណ្តៀងខៀវរួចហើយនៅក្នុងស្រែរបស់គាត់ ហើយគាត់ក៏បានសង្ឃឹមថានឹងស្វែងរកឃើញមធ្យោបាយដើម្បីរកត្បូងកណ្តៀងថែមទៀតនាពេលអនាគត។

បន្ទាប់ពីប្រមូលផលរួច សុភមង្គលថ្មីដែលកំពុងកើតមានបានផ្តល់ឲ្យភូមិនេះ។ទិន្នផលស្រូវនេះល្អគួរសម ថ្វីបើមានការពន្យាពេលសាបព្រោះ និងការដកស្ទូងក៏ដោយ។ អ្នកគ្រប់គ្នាបានកំពុងប្រារព្ធពិធីឆ្លង និងពូកគេមានសេចក្តីសប្បាយរីករាយ។មានតែសំបូរម្នាក់ប៉ុណ្ណោះ ដែលកំពុងត្រៀមរៀបចំសម្រាប់កិច្ចការស្រែចម្ការនាពេលអនាគតដោយក្តីឧស្សាហ៍ព្យាយាម គាត់ធ្វើហាក់ដូចជាភ្លៀងរដូវវស្សានឹងមកដល់អ៊ីចឹង។

ថ្ងៃមួយ គាត់បានស្ទូចត្រីធំៗទាំងអស់ចេញពីបឹងរបស់គាត់ដោយទុកតែត្រីតូចៗប៉ុណ្ណោះ។ គាត់បានរៀបចំពិធីជប់លៀងមួយសម្រាប់ក្រុមអ្នកជិតខាងរបស់គាត់។ដោយសារពួកគេខ្លះមិនដែលបានសូម្បីតែភ្លក់រសជាតិសាច់ត្រី ហើយនឹងអ្នកដែលមិនមានឱកាសបរិភោគវាអស់រយៈពេលជាយូរមកហើយ អ្នកគ្រប់គ្នាបានបរិភោគសាច់ត្រីយ៉ាងឆ្ងាញ់ពិសារ។

នៅថ្ងៃបន្ទាប់ សំបូរបានចាប់ផ្តើមបាចទឹកខ្លះចេញពីបឹងរបស់គាត់ទៅកាន់ស្រែរបស់គាត់។អំឡុងប៉ុន្មានថ្ងៃក្រោយ សំបូរនិងប្រពន្ធរបស់គាត់ដកសំណាបដែលពួកវាបានដុះចេញពីគ្រាប់ពូជស្រូវនៅស្រែដែលនៅពីក្រោយខ្ទមរបស់ពួកគាត់។សន្ទូងបានលូតលាស់យ៉ាងល្អដោយសារអាកាសធាតុក្តៅ និងការផ្គត់ផ្គង់យ៉ាងជាប់លាប់ពីទឹកដែលមកពីបឹង។ហេតុនេះ នៅពេលពេលផលាប្រមូលផលបានមកដល់ ទិន្នផលស្រូវរបស់សំបូរខ្ពស់ស្មើរតែស្មើមួយដងកន្លះ។

បន្ទាប់មក គាត់បានអញ្ជើញអ្នកជិតខាងជិតស្និទ្ធិពីរនាក់មកផ្ទះ ហើយប្រាប់ពួកគេថា៖ «ខ្ញុំនឹងឲ្យផលស្រូវពីររដូវប្រាំងពាក់កណ្តាលរបស់ខ្ញុំដល់ពួកអ្នក។អរគុណចំពោះស្រូវនេះ អ្នកនឹងអាចជីកបឹងពីរដូចគ្នា ដូចបឹងដែលខ្ញុំមាន ហើយទិញត្រីខ្លះសត្វទាខ្លះ និងក្ងានខ្លះ។វាអាស្រ័យលើអ្នកទេ ថាតើអ្នកចង់ជីកបឹងជាមួយគ្រួសាររបស់អ្នក ឬក៏ពឹងឲ្យក្រុមអ្នកជិតខាងជួយ

នឹងគ្មានបឹងស្រូវធំដូចនេះទេ នៅអំឡុងរដូវដាំដុះមុននោះ»។

អ្នកជិតខាងទីមួយនៃអ្នកជិតខាងពីរនាក់នោះបានផ្តល់ការងារឱ្យដល់អ្នកកសិករ១៦នាក់ដ៏ទៃទៀតក្នុងរយៈពេលពេញមួយខែ។ អ្នកជិតខាងទីពីរបានធ្វើការជាមួយគ្រួសារដែលមានសមាជិកច្រើននាក់របស់គាត់ពេញមួយរដូវប្រាំង។

នៅពេលរដូវភ្លៀងបន្ទាប់បានបង្អុរមក មានត្បូងកណ្តៀងពណ៌ខៀវបីគ្រាប់ដែលនៅលើវាលស្រែជុំវិញភូមិនេះ។ ត្រី សត្វទា និងក្ងានកំពុងមានសេចក្តីសុខសាន្តនៅក្នុងបឹងទាំងនោះ។ មនុស្សម្នាក់អាចមើលឃើញ ពីវិធីដែលហ្វូងក្រុមគ្រួសារសត្វទា និងកូនទាវ័យក្មេងខ្ចីហែលត្រាច់ចរកាត់តាមវាលស្រែដែលពេញព្រៀបដោយទឹកក្នុងរដូវវស្សា ហើយនឹងពីវិធីពួកគេចឹកស៊ីពពួកដង្កូវទឹក និងសត្វល្អិតចង្រៃជាច្រើនដោយប្រើចំពុះរបស់ពួកគេ ខណៈពួកគេដកសារ៉ាយពីបរិវេណដែលនៅក្បែរឫសដ៏រឹងមាំរបស់ដំណាំស្រូវដោយប្រើជើងដែលធ្វើចលនាហែលទឹករបស់ពួកវា។

មិនយូរប៉ុន្មានក្រុមកសិករអាចមានលទ្ធភាពទិញបានមេមាន់ខ្លះ និងសត្វជ្រូកខ្លះ។ សត្វទាំងនោះត្រូវគេផ្តល់ឱ្យទៅក្រុមគ្រួសារដែលនៅមិនទាន់មានបឹងមួយដូចគេ។

កសិករខ្លះបានជីកបឹងតូចជាង១ជាមុនសិន ដើម្បីធានាឱ្យមានយ៉ាងហោចណាស់មានការប្រមូលផលដ៏ល្អក្នុងឆ្នាំនិមួយៗ។ បើសិនជារដូវវស្សាមកយឺតជាថ្មី ឬមិនសូវមានភ្លៀងច្រើន នៅពេលស្រូវត្រូវការការបាចទឹកបញ្ចូលស្រែ ពួកគេនឹងត្រៀមជាស្រេច និងការពារទុកជាមុន។

ក្រៅពីនេះ ក្រុមកសិករដ៏ទៃទៀតបានជីកបឹងធំកាន់តែធំសម្រាប់ប្រើរួមជាមួយគ្រួសារជាច្រើន។ជួនកាល គេចាំបាច់ត្រូវក្រាល ដីឥដ្ឋនៅបាតបឹងឱ្យបានជាច្រើនស្រទាប់ជាមុនសិន ធ្វើដូច្នេះទឹកវាអាចជ្រាបចេញតែបន្តិចប៉ុណ្ណោះ។គេនិយមដាំដើមឈើហ៊ុបផ្ទៃជុំវិញបឹងដើម្បីកាត់បន្ថយការរំហួតទឹក។បន្ទាប់មកអ្នកភូមិបានដាក់ពពួកអណ្តើកកន្លាយនៅក្នុងបឹង ហើយដាក់គ្រាប់ពូជផ្កាឈូកនៅខាងក្នុងបឹង ដោយកាត់បណ្តូលរបស់វាបន្តិចសិនដើម្បីឱ្យវាត្រៀមដុះពន្លកឡើង។

អរគុណដល់សកម្មភាពការងារដ៏ឧស្សាហ៍ព្យាយាម នៅពេលអ្នកជិតខាងទាំងពីរបានឱ្យផលស្រូវរដូវប្រាំងដំបូងទៅគ្រួសារចំនួនពីរគ្រួសារទៀត និងគ្រួសារពីរនោះឱ្យផលស្រូវទៅដល់គ្រួសារដ៏ទៃទៀតនៅឆ្នាំជាបន្តបន្ទាប់ វាមិនមែនមានតែត្បូងកណ្តៀងខៀវ១៥គ្រាប់ដែលបញ្ចេញពន្លឺជុំវិញភូមិ ប៉ុន្តែបើតាមចំនួនពិតប្រាដក គឺសរុបទៅមានត្បូង១០៨គ្រាប់ ។

នៅក្នុងភូមិខ្លះ ប្រជាជនក៏បានបង្កើតប្រឡាយទឹកតូចជាច្រើនដោយនាំយកទឹកមកកាន់បឹងរបស់ពួកគេមកពីបឹងរាក់ៗ។ ទីកន្លែងជាច្រើនដែលនៅជុំវិញជនបទស្រុកស្រែនេះ ជាទីដែលទឹកដែលលើសត្រូវគេទប់នៅក្នុងតំបន់ដ៏ធំជាច្រើន បន្ទាប់ពីភ្លៀងរដូវវស្សាដែលកាលពីអតីតកាលបានហូតស្ងួតយ៉ាងឆាប់រហ័សដោយមិនត្រូវបានគេប្រើប្រាស់នោះ។

ភូមិមួយនៃភូមិនៅកាន់តែឆ្ងាយ នៅក្បែរទន្លេធំ ក្រុមកសិករអាចមានលទ្ធភាពអាចបង្កើតប្រឡាយទឹកតូចមួយទៅប្រឡាយទឹកមួយនៃនៅមែកធាងប្រឡាយទឹកនានាដែលនៅកៀកនឹងវាបំផុត។

សម្ដីរបស់កូនដំរីបានចាប់ផ្ដើមក្លាយជាការពិតថា៖«បើសិនជាអ្នកនឹងតែងតែមានក្ដីអាណិតអាសូរ និងសប្បុរស អ្នក និងអ្នកដើរតាមរបស់អ្នកនឹងរកត្បូងកណ្ដៀងបានច្រើនដូចគ្នានៅលើវាលស្រែរបស់អ្នក ហើយក្ដីឈឺចាប់ផទនាទាំងអស់នឹងត្រូវកាត់បន្ថយនៅក្នុងស្រុករបស់អ្នកសម្រាប់ជាច្រើនមនុស្សជំនាន់ក្រោយជាច្រើនដែលនឹងមកដល់ឮ»។

ហើយប្រជាជនបានធ្វើដូច្នេះមែន។ពីភូមិមួយទៅភូមិបន្ទាប់ ពីទីប្រជុំជនមួយទៅទីប្រជុំជនមួយទៀត រំលងពីភ្នំនានា ហើយនឹងជ្រលងភ្នំជាច្រើន តាមបណ្ដោយតំបន់នេះជាទីតំបន់អង្គរដ៏ល្អឥតខ្ចោះជាមួយព្រះភក្ត្រដ៏មានសន្តិភាពនៃប្រាសាទបាយ័ននឹងពីអតីតកាលអាចត្រូវកសាងដោយស្ដេចដ៏អស្ចារ្យក្នុងពេលអនាគត ដល់ប្រទេសដែលគួរឲ្យគោរពដ៏ទៃទៀតរបស់ក្រុមដំរីដ៏ផ្សេងៗ  ហើយនឹងបន្ទាប់ប្រទេសកាន់តែឆ្ងាយ ហើយឆ្ងាយនៅជុំវិញពិភពលោក។ដល់ចំពោះអ្នកទាំងឡាយដែលពិតជាបានត្រូវការការជួយប្រាកដមែន។

ហើយហេតុនេះវាបានកំពុងកើតឡើងគ្រប់ទីកន្លែងនៅក្នុងពិភពលោកនេះរហូតមកទល់សព្វថ្ងៃនេះ។

ពិតមែនហើយ អ្នកពិតជាដឹងយ៉ាងជ្រាលជ្រៅពីខណៈពេលដ៏អស្ចារ្យនេះដែលអតីតកាល និងអនាគតលាយឡំជាមួយបច្ចុប្បន្នកាល ដែលនៅទ្រឹង ដែលជារាំងនន និងច្រកទ្វារចូល ច្រកទ្វារចូលមន្តអាគមទៅកាន់សុភមង្គល។ អ្នកបានបើកវារួចហើយសម្រាប់អ្នកដ៏ទៃទៀតជាច្រើនលើកមកហើយ។

ខ្ញុំដឹងអំពីវាច្បាស់ណាស់
ខ្យល់ជំនោរអមតៈពាំនាំរឿងរ៉ាវរបស់អ្នកតាមស្លាបរបស់វា
គាត់ចូលចិត្តនិទានរឿងវាប្រាប់ដល់ផ្កាឈូកនៅក្នុងស្រុកបឹងត្បូងកណ្ដៀងខៀវ និងស្រុករបស់មនុស្សលោក

អរគុណច្រើន

បកប្រែដោយ ម៉ី ភីនី